ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១២ សហវ.....

## សារាចរ
## ស្តីពី
## គោលការណ៍ណែនាំបន្ថែមលើរយៈពេល សោហ៊ុយធ្វើដំណើរ តម្លៃសំបុត្រយន្តហោះ ចំពោះការបំពេញបេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ

ដើម្បីពង្រឹងនិងបង្កើន ប្រសិទ្ធភាព គណនេយ្យភាព សង្គតិភាព ភាពសន្សំសំចៃ និងតម្លាភាព នៃការអនុវត្តចំណាយលើបេសកកម្មក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងខ្លឹមសារនៃប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់គោលការណ៍ណែនាំបន្ថែម ដូចខាងក្រោម÷

១- ក្រសួង ស្ថាប័ន ដែលមានតម្រូវការបំពេញបេសកកម្មក្នុងនិងក្រៅប្រទេសលើសពីចំនួន កំណត់ ១០ ថ្ងៃ ក្នុងមួយខែ ត្រូវរៀបចំផែនការបេសកកម្ម ក្នុងនិងក្រៅប្រទេស ដែលលើសចំនួនថ្ងៃកំណត់ សម្រាប់ឆ្នាំថវិកានីមួយៗ ដោយត្រូវបញ្ជាក់ជាអាទិ៍ចំណាយលម្អិត និងទឡ្ហីករណ៍ ដែលជាមូលហេតុនៃបេសកកម្មលើសពីចំនួនថ្ងៃកំណត់ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងអនុម័ត។ ក្នុងករណី មានបេសកកម្មលើសពី ១០ ថ្ងៃ ក្នុងមួយខែ ដែលពុំបានគ្រោងទុកក្នុងផែនការបេសកកម្ម ក្រសួង ស្ថាប័ន ត្រូវស្នើសុំជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវគោលការណ៍អនុញ្ញាតដោយឡែក តាមករណីជាក់ស្តែងនីមួយៗ។

តារាងផែនការបេសកកម្មក្នុងនិងក្រៅប្រទេស ដែលលើសចំនួន ១០ថ្ងៃ ក្នុងមួយខែ ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃសារាចរនេះ។

២- ជាគោលការណ៍ សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មក្នុងប្រទេស ត្រូវផ្តល់ជូនជាសាច់ប្រាក់។ ចំពោះបេសកកម្មដែលមានគោលដៅដោយឡែក និងត្រូវប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ដូចជា ការបង្ក្រាបបទល្មើស ការស្រាវជ្រាវបទល្មើស ការស៊ើបអង្កេតបទល្មើស អធិការកិច្ច និងការសង្គ្រោះនានា ប្រេងឥន្ធនៈអាចត្រូវបានឧបត្ថម្ភបន្ថែម តាមរបបដោយឡែក ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃធនធានប្រេងរបស់សាមីក្រសួង ស្ថាប័ន។ ដោយឡែកសម្រាប់ឆ្នាំ២០១៥ សោហ៊ុយធ្វើដំណើរអាចផ្តល់ជូន ជាប្រេងឥន្ធនៈតាមទំហំសមមូលទៅនឹងចំនួនសាច់ប្រាក់នៃសោហ៊ុយធ្វើដំណើរ ដោយផ្អែកតាមចរិតលក្ខណៈនៃបេសកកម្ម និងលទ្ធភាពជាក់ស្តែងនៃឥណទានថវិកាសម្រាប់ប្រេងឥន្ធនៈរបស់សាមីក្រសួង ស្ថាប័ន នីមួយៗ។

៣- ក្រសួង ស្ថាប័នត្រូវទិញសំបុត្រយន្តហោះ សម្រាប់បំពេញបេសកកម្មក្រៅប្រទេស តាមតម្លៃ ឬជាមួយក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ដែលត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីដែលពុំត្រូវបាន


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

កំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាមីក្រសួង ស្ថាប័នត្រូវទិញសំបុត្រយន្តហោះ ដោយផ្អែកលើគោលការណ៍ដូចខាងក្រោម÷

- ប្រើប្រាស់ជើងហោះហើរត្រង់ និងក្នុងតម្លៃសន្សំសំចៃបំផុត
- កក់សំបុត្រយន្តហោះឱ្យបានមុនពីចំងាយ ដើម្បីទទួលបានតម្លៃសន្សំសំចៃបំផុត
- ជ្រើសរើសក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ស្របច្បាប់ និងមានតម្លៃប្រកួតប្រជែងខ្ពស់។

៤- ការបំពេញមុខងារ និងភារកិច្ចរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យា ដោយមានបម្លាស់ទីក្នុងរង្វង់ដែនដី នៃរាជធានី ក្រុង ឬស្រុក ដែលសាមីខ្លួនបំពេញមុខងារជាប្រក្រតី ពុំត្រូវចាត់ទុកជាបេសកកម្មឡើយ  ប៉ុន្តែអាចធ្វើជាកម្មវត្ថុនៃការផ្តល់ប្រាក់ឧបត្ថម្ភដោយឡែក  ដោយផ្អែកលើចរិតលក្ខណៈចាំបាច់នៃការបំពេញភារកិច្ច និងលទ្ធភាពជាក់ស្តែង នៃថវិការបស់ក្រសួង ស្ថាប័ននីមួយៗ ដោយត្រូវស្នើសុំគោលការណ៍អនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមករណីជាក់ស្តែងនីមួយៗ។

ទទួលបានសារាចរនេះ នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តសារាចរនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ